**UNITED NATIONS**
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

**NATIONS UNIES**
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

អង្គការសហប្រជាជាតិ
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

COHCHR

# សេចក្តីថ្លែងការណ៍ ដោយការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា

ថ្ងៃនេះយើងប្រារព្ធរៀបចំទិវាអន្តរជាតិ ដើម្បីជនជាតិដើមភាគតិចលើពិភពលោក ហើយយើងធ្វើការរំលឹកទិវានេះនៅប្រទេសកម្ពុជាលើកដំបូងបង្អស់ ។

អ្នករាយការណ៍ពិសេស ទទួលបន្ទុកជនជាតិដើមភាគតិចនៃគណៈកម្មាធិការសិទ្ធិមនុស្ស បានគូសបញ្ជាក់នៅក្នុងកិច្ចសម្ភាសន៍មួយនាពេលថ្មីៗនេះថា បញ្ហាធំបំផុតនៅទូទាំងពិភពលោកនេះ សំរាប់ជនជាតិភាគតិចគឺបញ្ហាដីធ្លី និងសិទ្ធិប្រើប្រាស់ដីធ្លី និងទ្រព្យសម្បត្តិ ។ បញ្ហានេះក៏កើតមានផងដែរនៅប្រទេសកម្ពុជា ។

ទិវានេះបានផ្តល់ឱកាសឱ្យយើងធ្វើការពិនិត្យឡើងវិញ និងសំរាប់ប្រទេសកម្ពុជា ក្នុងការប្តេជ្ញាចិត្តរបស់ខ្លួនជាថ្មីដើម្បីអនុវត្តឱ្យស្របតាមគោលនយោបាយជាតិ សំរាប់ជនជាតិដើមភាគតិចរបស់ខ្លួន ។

ច្បាប់អន្តរជាតិ ផ្តល់កិច្ចការពារជាពិសេសដល់ជនជាតិដើមភាគតិច ។ នៅក្នុងរបាយការណ៍ថ្មីបំផុតរបស់ លោកភីធីរ លយប្រែកតី តំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ដែលបានដាក់ជូនគណៈកម្មាធិការសិទ្ធិមនុស្ស បានអំពាវនាវឱ្យប្រទេសកម្ពុជា ចូលជាសមាជិកនៃអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិ (ILO) លេខ ១៦៩ ដែលជាកិច្ចព្រមព្រៀងអន្តរជាតិមួយ មានលក្ខណៈទូលំទូលាយបំផុត ដែលការពារសិទ្ធិរបស់ជនជាតិដើមភាគតិច និងពួកកុលសម្ព័ន្ធ ដើម្បីធានាការពារច្បាប់ និងប្រពៃណីទំនៀមទំលាប់ផ្ទាល់របស់ពួកគេ នៅក្នុងសង្គមជាតិនានាដែលពួកគេរស់នៅ[១] ។

ប្រទេសកម្ពុជា បានចូលជាសមាជិកនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិធំៗជាច្រើន ដែលធានាការពារសិទ្ធិមនុស្សជាមូលដ្ឋានសំរាប់ជនគ្រប់រូប រួមទាំងជនជាតិដើមភាគតិចផងដែរ ។ សិទ្ធិទាំងនោះរួមមានសិទ្ធិខាង អប់រំ សុខភាព និងសិទ្ធិមានជីវភាពរស់នៅសមរម្យ ។ នៅក្នុងឆ្នាំ១៩៩៨ គណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រកាន់ពូជសាសន៍ បានស្នើឱ្យប្រទេសកម្ពុជាទទួលស្គាល់សិទ្ធិប្រើប្រាស់ដីធ្លី ព្រៃឈើ និងធនធានធម្មជាតិដទៃទៀតរបស់ជនជាតិដើមភាគតិច និងអត្តសញ្ញាណវប្បធម៌ និងរបៀបរបបរស់នៅដាច់ដោយឡែក និងមានតែមួយគត់របស់ពួកគេ[២] ។ នៅឆ្នាំ១៩៩៩ គណៈកម្មាធិការសិទ្ធិមនុស្ស បានស្នើឱ្យគោរពសិទ្ធិជនជាតិដើមភាគតិចកម្ពុជា ក្នុងការទទួលបាននូវប្រពៃណីវប្បធម៌ រួមទាំងសកម្មភាពកសិកម្មរបស់ពួកផងដែរ[៣] ។ អនុសាសន៍ទាំងនេះ នៅមិនទាន់បានអនុវត្តនៅឡើយទេ ។

ពាក្យបណ្តឹងជាច្រើន អំពីការរំលោភសិទ្ធិមនុស្ស ដែលប៉ះពាល់ជនជាតិដើមភាគតិចកម្ពុជា ត្រូវបានរាយការណ៍ដោយលោកតំណាងពិសេសទីមួយ ម៉ៃឃើល ឃើប៊ី ក្នុងរបាយការណ៍របស់លោក ដាក់ជូនគណៈកម្មាធិការសិទ្ធិមនុស្ស

---

[១] សូមមើលរបាយការណ៍ ដាក់ជូនសម័យប្រជុំលើកទី៦១ នៃគណៈកម្មាធិការសិទ្ធិមនុស្ស (E/CN.4/2005/116 ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៤) ។

[២] គណៈកម្មាធិការក៏បានស្នើឱ្យប្រទេសកម្ពុជាចាត់វិធានការនានា ដើម្បីអនុវត្តយ៉ាងពេញទំហឹង នូវអនុសាសន៍ទូទៅរបស់ខ្លួន លេខ២៣ ដែលលើកឡើងអំពីសិទ្ធិរបស់ជនជាតិដើមភាគតិច ក្រោមអនុសញ្ញា ។ សេចក្តីសន្និដ្ឋានចុងក្រោយលេខ CERD/C/304/ Add.54 កថាខ័ណ្ឌ១៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៨ ។

[៣] សេចក្តីសន្និដ្ឋានចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិមនុស្ស, កម្ពុជា , ឯកសាររបស់អ.ស.ប CCPR/C/79/Add.108 (1999) ។

#10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587
E-mail: cohchr@online.com.kh Internet: www.unhchr.ch/cambodia

ឆ្នាំ១៩៩៦[៤] ។ បញ្ហាទាំងនេះ ស្ថិតនៅជាកង្វល់ដល់លោកតំណាងពិសេសទីពីរ គឺលោក ថូម៉ាស់ហាំម៉ាប៊ឹក ដែលបាន សរសេរនៅក្នុងរបាយការណ៍របស់លោកឆ្នាំ១៩៩៩ ដាក់គណៈកម្មាធិការសិទ្ធិមនុស្ស ដែលមានសេចក្តីថា :

*"សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច ក្នុងការទទួលបានការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិ ដែលជាប្រភពដ៏សំខាន់នៃការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគេនោះ កំពុងស្ថិតក្នុងការគំរាមកំហែង មិនត្រឹមតែដោយសារការកាប់ឈើ និងការធ្វើចំការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោយសារការរំលោភយកដីធ្លី តាមរូបភាពជាច្រើនប្រភេទដូចជា : ការឱ្យលុយកាក់ដល់សមាជិកទន់ខ្សោយបំផុតនៃសហគមន៍ ការសន្យាក្លែងក្លាយ ការបញ្ចុះបញ្ចូល ឬគ្រាន់តែជាការបំភិតបំភ័យ និងអំពើហឹង្សា"[៥] ។*

បញ្ហាទាំងនេះនៅតែបន្តកើតមាន ។ អនុសាសន៍របស់លោកតំណាងពិសេស នៅតែលើកឡើងអំពីបញ្ហាទាំងនេះ

ច្បាប់ភូមិបាលឆ្នាំ២០០១ ទទួលស្គាល់កម្មសិទ្ធិសមូហភាព ដែលត្រូវតែបង្កើតឱ្យមាននៅមុនការទាមទារណាមួយផ្សេងទៀត ដែលធ្វើទៅលើដីស្របច្បាប់សំរាប់ការផ្តល់កម្មសិទ្ធិសមូហភាព ។ ទោះជាយ៉ាងណាក៏ដោយអនុក្រឹត្យពាក់ព័ន្ធ និងអនុក្រឹត្យសំខាន់៧ដទៃទៀត សំរាប់អនុវត្តច្បាប់ភូមិបាល នៅតែត្រូវការការអនុម័ត និងច្បាប់សំរាប់កំណត់លក្ខណៈវិនិច្ឆ័យអំពីឋានៈរបស់ជនជាតិដើមភាគតិច នៅតែកំពុងរៀបចំព្រាងដោយក្រសួងមហាផ្ទៃនៅឡើយ ។

លោកតំណាងពិសេសទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាទាំងអស់បានអះអាងថា ជនជាតិដើមភាគតិចកម្ពុជាកំពុងតែក្លាយទៅជាជនងាយរងគ្រោះខ្លាំងឡើងថែមទៀតចំពោះការរឹបអូសដីធ្លី និងការផ្ទេរសិទ្ធិគ្រប់គ្រងដីធ្លីស្របច្បាប់របស់ពួកគេ ។ បច្ចុប្បន្ននេះ គេមានសេចក្តីព្រួយបារម្ភយ៉ាងខ្លាំងថា ដីនឹងនៅសេសសល់តិចតួច ដើម្បីផ្តល់កម្មសិទ្ធិ នៅពេលដែលអនុក្រឹត្យទាំងនេះ និងច្បាប់សំខាន់៧ដទៃទៀតត្រូវបានអនុម័ត ។ លោកតំណាងពិសេសបច្ចុប្បន្ន បានអំពាវនាវសុំឱ្យផ្អាកការផ្តល់ដីសម្បទានគោលដៅសេដ្ឋកិច្ចតទៅទៀត ហើយការចុះបញ្ជីកម្មសិទ្ធដីធ្លីជាលក្ខណៈបុគ្គលត្រូវហាមឃាត់លើដីរដ្ឋដែលសមស្របសំរាប់ការផ្តល់កម្មសិទ្ធិសមូហភាពសំរាប់ជនជាតិដើមភាពតិច ដោយរង់ឱ្យចាំរហូតដល់អនុក្រឹត្យទាំងឡាយដែលពាក់ព័ន្ធ ចូលជាធរមានជាមុនសិន ។

ទិវាទនេះអនុញ្ញាតឱ្យយើងទាំងអស់គ្នា ធ្វើការប្តេជ្ញាចិត្តជាថ្មី ដើម្បីធ្វើការកែប្រែជីវភាពឱ្យបានកាន់តែប្រសើរឡើងដល់ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា ។ ចំពោះបញ្ហានេះ  វាគឺជាការចាំបាច់ណាស់ សំរាប់ជនជាតិដើមភាគតិចក្នុងការចូលរួមយ៉ាងពេញទំហឹង និងត្រូវមានការពិភាក្សាឱ្យបានល្អិតល្អន់មុននឹងធ្វើការសំរេច លើបញ្ហាទាំងឡាយដែលប៉ះពាល់ដល់ពួកគេ ។ នេះគឺដើម្បីលើកស្ទួយ និងគោរពសិទ្ធិរបស់ជនជាតិដើមភាគតិច ក្នុងការបង្កើតសមាគមការរួមប្រជុំ សេរីភាពក្នុង ការដើរហើរដោយសេរី និងសេរីភាពក្នុងការផ្លាស់ប្តូរមតិយោបល់ និងព័ត៌មានដោយសេរី ។ មិនមានហេតុផលត្រឹមត្រូវណាមួយ ដែលត្រូវធ្វើការរិតត្បិតដល់ការអនុវត្តន៍សិទ្ធិទាំងនេះ នៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះទេ ។

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ត្រៀមខ្លួនជានិច្ច ដើម្បីធ្វើការជាមួយរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងទីភ្នាក់ងារអន្តរជាតិនានា និងជាមួយជនជាតិដើមភាគតិចកម្ពុជាដើម្បី បង្កើតនិងអនុវត្តគោលនយោបាយជាតិដ៏ត្រឹមត្រូវ ដែលគោរពអត្តសញ្ញាណវប្បធម៌ និងរបៀបរបបរស់នៅរបស់ពួកគេ និងធានាដល់ការអនុវត្តសិទ្ធិមនុស្សរបស់ខ្លួន ។

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ថ្ងៃទី ៩ ខែ សីហា ឆ្នាំ២០០៥ ។

---

[៤] របាយការណ៍របស់លោកតំណាងនៃលោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ដាក់ជូនគណៈកម្មាធិការសិទ្ធិ មនុស្ស (UN Doc., E/CN.4/1996/93, ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៩៦) ។

[៥] របាយការណ៍ ដាក់ជូនគណៈកម្មាធិការសិទ្ធិមនុស្ស ស្តីពីសភាពការណ៍សិទ្ធិមនុស្សនៅកម្ពុជា, ឯកសាររបស់អ.ស.ប លេខ E/CN.4/1999/101 ចុះថ្ងៃទី២៦ ខែកម្ភៈ ឆ្នាំ១៩៩៨ កថាខ័ណ្ឌ ១៣២ ។